00277469 **Declassified to Public**
**06 September 2012**

E2/47/2

# ការតែងតាំង និង លក្ខខណ្ឌក្នុងការចូលរួម

ការតែងតាំងអ្នកតំណាងផ្នែកច្បាប់នៅក្នុងសវនាការប្រឆាំងនឹងជនត្រូវចោទ កាំង ហ្គេចអ៊ាវ (ហៅ"ឌុច")
នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ០០១ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក)
និង យោងទៅតាមវិធាន២៣, ៨៣, និង ១០០ នៃវិធានផ្ទៃក្នុងអ.វ.ត.ក.

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. A. Tly

| | | | |
|---|---|---|---|
| នាមត្រកូលៈ | ចិង | នាមខ្លួនៈ | ឡាយ |
| ថ្ងៃខែឆ្នាំកំណើត អាយុៈ | 78 ឆ្នាំ | | |
| អាសយដ្ឋានៈ | ភូមិចំពោកប៉ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល. | | |
| ទូរស័ព្ទៈ | 016 38 96 28 / 016 48 12 23. | | |

តាមរយៈនេះ ខ្ញុំសូមតែងតាំងមេធាវីសញ្ជាតិកម្ពុជា កញ្ញា ទី ស្រ៊ីនណា ជាសហមេធាវីជាតិរបស់ខ្ញុំ នៅក្នុងសវនាការចាប់ពីថ្ងៃតែងតាំងនេះរហូតដល់ថ្ងៃបញ្ចប់សវនាការ ។ កញ្ញា ស្រ៊ីនណា ត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំនឹងតែងតាំងសហមេធាវីអន្តរជាតិមួយរូបជាអ្នកដឹកនាំក្រុមការពារក្តីនៅក្នុងពេលឆាប់ៗខាងមុខនេះ ។

ខ្ញុំអនុញ្ញាតឲ្យសហមេធាវីជាតិទទួលយកឯកសារគ្រប់ប្រភេទទាក់ទងនឹងរឿងក្តីរបស់ខ្ញុំ ។

ជាងនេះទៅទៀត ខ្ញុំផ្តល់ឲ្យសហមេធាវីជាតិនូវសិទ្ធិក្នុងការផ្ទេរអំណាចដែលបានផ្តល់ឲ្យតាមរយៈនេះទៅកាន់មេធាវីជាតិ និង/ឬ អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ រហូតដល់ពេលដែលខ្ញុំបានតែងតាំងសហមេធាវីអន្តរជាតិជាអ្នកដឹកនាំក្រុមការពារក្តី ខ្ញុំទទួលស្គាល់ថា សហមេធាវីជាតិមានអំណាចក្នុងការតែងតាំងក្រុមការងារមួយដើម្បីជួយ និង គាំទ្រការបំពេញភារកិច្ចជាសហមេធាវីជាតិរបស់ខ្ញុំ ។ រហូតដល់ពេលដែលខ្ញុំបានតែងតាំងសហមេធាវីអន្តរជាតិជាអ្នកដឹកនាំក្រុមការពារក្តី ខ្ញុំអនុញ្ញាត [illegible] ពេញលេញទៅលើការតែងតាំង និង ការគ្រប់គ្រងលើក្រុមអ្នកការពារក្តីរបស់ខ្ញុំ ។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C. A. Tly

ជាពិសេស ខ្ញុំអនុញ្ញាតឲ្យសហមេធាវីជាតិរបស់ខ្ញុំតែងតាំងមេធាវីអន្តរជាតិដូចតទៅនេះ ជាផ្នែកមួយនៃក្រុមអ្នកការពារក្តីរបស់ខ្ញុំៈ លោក ការីម ខាន (មកពីចក្រភពអង់គ្លេស) លោក អាឡាំង វើនើ (មកពីប្រទេសស្វីស) និង កញ្ញា ប្រ៊ីអាន់ មិកហ្គូនីហ្គល (មកពីសហរដ្ឋអាមេរិក) ។

នៅក្នុងការផ្តល់ការតំណាងផ្នែកច្បាប់នេះ សហមេធាវីជាតិនឹងបំពេញការងារប្រកបដោយសមត្ថភាព ឯករាជ្យភាព ដោយមានការយកចិត្តទុកដាក់ និង ការប្រុងប្រយ័ត្នយ៉ាងសមរម្យ និង សមស្របតាមបទដ្ឋានវិជ្ជាជីវៈខ្ពស់បំផុត និង ក្រមសីលធម៌ ។ សហមេធាវីជាតិសន្យាថានឹងមិនចូលរួមនៅក្នុងសកម្មភាព ឬ ការប្រព្រឹត្តណាមួយដែលមិនសមស្រប ទៅនឹងការបំពេញកាតព្វកិច្ចរបស់គាត់ និង ទៅនឹងសុចរិតភាពនៃវិជ្ជាជីវៈច្បាប់ ។

នៅពេលការពារក្តីឲ្យអតិថិជន នៅក្នុងចំណោមកិច្ចការផ្សេងៗទៀត សហមេធាវីជាតិត្រូវៈ

(i) គោរពការសម្រេចចិត្តរបស់អតិថិជនទាក់ទងនឹងគោលបំណងនៃការការពារក្តី

(ii) ពិគ្រោះយោបល់ជាមួយអតិថិជនអំពីមធ្យោបាយក្នុងការសម្រេចគោលបំណងទាំងនេះ ប៉ុន្តែ មិនចងដោយការសម្រេចចិត្តរបស់អតិថិជនទេ

(iii) ស្វែងរក ឬ ទទួលយកតែការណែនាំទាំងឡាយណាដែលចេញពីអតិថិជន និង ដែលមិនមែនដោយសារតែមានការបញ្ចុះបញ្ចូលពីនរណាម្នាក់ អង្គការ ឬ រដ្ឋណាមួយ ។

(iv) បំពេញការងារដោយសហការណ៍ជាមួយសហមេធាវីអន្តរជាតិដែលជាអ្នកដឹកនាំក្រុមការពារក្តី(បន្ទាប់ពីបានតែងតាំងរួច) ដើម្បីផលប្រយោជន៍ល្អបំផុតរបស់អតិថិជន ។

ខ្ញុំសន្យាផ្តល់ជាបន្ទាន់ដល់សហមេធាវីជាតិនូវការណែនាំយ៉ាងពេញលេញរបស់ខ្ញុំ និង ព័ត៌មានចាំបាច់ទាំងអស់តាមការស្នើសុំ នៅក្នុងអំឡុងពេលនៃការការពារក្តី ។ ទំនាក់ទំនងរបស់យើងគឺជាទំនាក់ទំនងឯកជន និង ជាការសម្ងាត់ ហើយជានិច្ចកាលត្រូវសមស្របទៅនឹងក្រមសីលធម៌ ។ សហមេធាវីជាតិនឹងត្រូវជូនដំណឹងដល់ខ្ញុំឲ្យបានសមរម្យអំពីស្ថានភាព និង ដំណើរការវិវត្តន៍របស់សំណុំរឿង ។

តាមរយៈនេះ ខ្ញុំសូមធ្វើការស្នើសុំឲ្យតុលាការទទួលស្គាល់ជាផ្លូវការថា កញ្ញា ទី ស្រ៊ីនណា ជាសហមេធាវីជាតិរបស់ខ្ញុំ ចាប់ពីថ្ងៃនេះតទៅ ។ ខ្ញុំនឹងព្យាយាមជូនដំណឹងទៅតុលាការអំពីការជ្រើសរើសសហមេធាវីអន្តរជាតិរបស់ខ្ញុំឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

E2/47/2

ហត្ថលេខា ឬ ស្នាមមេដៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកដែលត្រូវបានទទួលស្គាល់ឲ្យធ្វើជាតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីៈ

ឈ្មោះៈ ចឹម ឡាយ. (ដើមបណ្តឹងរដ្ឋប្បវេណី)

កាលបរិច្ឆេទៈ ២៣ ធ្នូ ២០០៨. (ថ្ងៃ/ខែ/ឆ្នាំ)

ធ្វើនៅៈ កណ្តាល. (ខេត្ត/ក្រុង, ប្រទេស)

ហត្ថលេខារបស់សហមេធាវីជាតិៈ

AVOCAT ATTORNEY AT LAW

ឈ្មោះៈ កញ្ញា ទី ស្រ៊ីនណា (សហមេធាវីជាតិ)

កាលបរិច្ឆេទៈ 31-ធ្នូ-2008 (ថ្ងៃ/ខែ/ឆ្នាំ)

ធ្វើនៅៈ ភ្នំពេញ (ខេត្ត/ក្រុង, ប្រទេស)